# ព្រាបសន្តិភាព

ព្រឹត្តិបត្រព្រាបសន្តិភាព អ្វីៗដើម្បីសន្តិភាព ឆ្នាំទី២ លេខ ១០



## ឪពុកម្តាយល្អ បង្កលក្ខណៈអោយកូនបានចេះដឹង


❖ ស្រលាញ់កូនត្រូវផ្តល់ឪកាសឲ្យកូនចូលសាលារៀន..................... ទំព័រទី ១

❖ កុមារីពាយ ពាត ចង់ក្លាយជាគ្រូពេទ្យ............................ ទំព័រទី ៣

❖ ប្រសិទ្ធិភាពប្រាក់កម្ចីរបស់សមាគមសាមគ្គីកសិករក្រីក្រ...... ទំព័រទី ៦

❖ ការដក់បារីជាមូលហេតុបណ្តាលឲ្យមានជំងឺជាច្រើន........ ទំព័រទី ៨

N”10.qxd 06/16/2006 10:06 Morning Page II



N"10.qxd 06/16/2006 10:06 Morning Page III

# ឪពុកម្តាយល្អបង្កលក្ខណៈ អោយកូនបានចេះដឹង

មនុស្សម្នាក់ៗដែលកើតមកមិនអាចមានសមត្ថភាពដោយខ្លួនឯងក្នុងការទទួលបានចំណេះដឹងខ្ពង់ខ្ពស់ និងអនាគតល្អបានឡើយ បើគ្មានការខិតខំឧបត្ថម្ភលើកទឹកចិត្តពីសំណាក់ឪពុកម្តាយ ឬអាណាព្យាបាលរបស់ខ្លួននោះ ។ ឪពុកម្តាយល្អតែងតែគិតបារម្ភពីអនាគតរបស់កូនខ្លួនចង់អោយកូនទទួលបានអនាគតល្អប្រសើរនិងជីវភាពរស់នៅសុខស្រួល ។ ដូចតួយ៉ាង បងប្រុស ជា ផុន និងបងស្រី មាសមានដែលមានកូនចំនួនប្រាំនាក់ប្រកបមុខរបរជាអ្នករត់ម៉ូតូឌុបនិងលក់កំពឹងគ្នោតរស់នៅភូមិស្តុកឃុំភ្នំបាតស្រុកពញាឮខេត្តកណ្តាលបានប្រឹងប្រែងអោយកូនបានរៀនសូត្រចេះដឹងគ្រប់ៗគ្នាគឺកូនប្រុសច្បងរៀនថ្នាក់ទី១១ កូនស្រីបន្ទាប់រៀនថ្នាក់ទី៨និងកូនទីបីប្រុសរៀនថ្នាក់ ទី៤ ឯកូនទី៤ និងទី៥នៅតូចនៅឡើយមិនទាន់ចូលរៀនទេ ។ បងប្រុស**ជា ផុន** បាននិយាយរៀបរាប់ពីការលំបាកក្នុងការចិញ្ចឹមកូនព្រោះបងប្រុសមានម៉ូតូចាស់មួយគ្រឿងដើម្បីប្រកបមុខរបរជាអ្នករត់ម៉ូតូឌុប ម្ល៉ោះហើយតំរូវអោយកូនៗទាំងអស់ក្រៅពីម៉ោងរៀនសាលាត្រូវជួយកាប់កាប់កំពឹងគ្នោតលក់ឧបត្ថម្ភការរៀនសូត្ររបស់ខ្លួន ។ នៅក្នុងគ្រួសារគាត់ មនុស្សនៅក្នុងគ្រួសារត្រូវមានការខិតខំប្រឹងប្រែង ឧស្សាហ៍ព្យាយាមទាំងអស់គ្នាទើបបាន ព្រោះចំណូលក្នុងគ្រួសាររួមគ្នាបានត្រឹមតែ១៥០០០រៀល ឯចំណាយវិញអស់១០០០០រៀល នៅសល់ត្រឹមតែ៥០០០រៀល ប៉ុណ្ណោះយ៉ាងច្រើនក្នុងមួយថ្ងៃ ។ ប៉ុន្តែក្នុងទឹកចិត្តជាឪពុកម្តាយគាត់តែងចាប់អារម្មណ៍ណែនាំកូនតាំងពីនៅតូចៗដោយប្រព្រឹត្តអំពើល្អជាគំរូដល់កូននិងចៀសវាងការប្រើអំពើហិង្សាលើកូនធ្វើយ៉ាងណាអោយកូនយល់នូវទឹកចិត្តស្រលាញ់របស់ឪពុកម្តាយពេលនោះកូនៗនឹងអាណិតឪពុកម្តាយ ហើយជួយធ្វើការ និងស្តាប់បង្គាប់ឪពុកម្តាយវិញជាពិតប្រាកដ ។ ឯកំលាំងចិត្តដែលជំរុញអោយគាត់ខិតខំមិនចេះនឿយហត់នោះគឺអនាគតកូនៗទាំងអស់របស់គាត់ ដែលគាត់ចង់អោយមានចំណេះគ្រប់ៗគ្នាដើម្បីរស់នៅក្នុងសង្គមបានស្រួលមិនពិបាកវេទនាដូចជារូបគាត់ ។ គាត់សូមជូនជាមតិដល់ឪពុកម្តាយទាំងឡាយដែលមិនបានយកចិត្តទុកដាក់ណែនាំលើកទឹកចិត្តកូនអោយទៅរៀននោះ ដោយលើកជាសុភាសិតថា **"សាច់មិនបានស៊ី បែរជាយកឆ្អឹងព្យួរកជំនួសវិញ"** ព្រោះថាបើថ្ងៃក្រោយកូនចៅវេទនាគឺយើងជាឪពុកម្តាយនឹងជួបប្រទះការលំបាកកាន់តែខ្លាំងឡើងទៀតតែបើកូនចេះដឹងវិញវានឹងផ្តល់កិត្តិយសជូនគ្រួសារហើយវានឹងមានជីវភាពធូរធារផង ។ គាត់បានពោលទៀតថា ឪពុកម្តាយគឺជាប្រទីបបំភ្លឺផ្លូវដល់កូនៗតាមរយៈបទពិសោធន៍ក្នុងជីវិតដែលខ្លួនបានឆ្លងកាត់គឺមិនត្រូវមានភាពអយុត្តិធម៌ក្នុងការលើកទឹកចិត្តកូនអោយទៅរៀនសូត្រនោះទេ ព្រោះខ្លួនបានជាល្ងង់ទៅហើយ ។ តែទន្ទឹមនឹងការដឹកនាំកូនក្នុងគ្រួសារអោយប្រព្រឹត្តអំពើល្អ និងចេះស្រលាញ់ជួយការងារក្នុងជីវភាពឪពុកម្តាយក៏មិនត្រូវរំលងក្នុងការណែនាំកូនអោយចៀសវៀងមជ្ឈដ្ឋានអាក្រក់ពីខាងក្រៅ ដូចជាការសេពគប់មិត្តភក្តិមិនល្អ ដោយធ្វើការតាមដានការសិក្សារបស់កូន និងហាមប្រាមកូនកុំអោយសេពគប់មិត្តភក្តិមិនល្អ ឬដើរលេងយប់ឡើយ ។

ជាចុងក្រោយ គាត់បានសំណូមពរដល់លោកគ្រូអ្នកគ្រូដែលជាឪពុកម្តាយទីពីររបស់សិស្សសូមមេត្តាយកចិត្តទុកដាក់បង្ហាត់បង្រៀនសិស្សអោយបានល្អផងព្រោះកូនក្មេងត្រូវការចំណេះវិជ្ជាច្បាស់លាស់ទុកជាស្ពានក្នុងការកសាងខ្លួន ។ គាត់ក៏សំណូមពរដល់ក្រសួងអប់រំ ក៏ដូចជារាជរដ្ឋាភិបាលផងដែរសូមជួយយកចិត្តទុកដាក់ដោះស្រាយប្រាក់ខែគ្រូអោយបានគ្រប់គ្រាន់ផងដើម្បីគ្រូមានស្មារតីបង្រៀនសិស្សអោយអស់ពីសមត្ថភាព ព្រោះឪពុកម្តាយដែលល្ងង់គ្មានសមត្ថភាពបង្រៀនកូនខ្លួន តទំព័រទី៤

# ខ្ញុំចង់ធ្វើជាគ្រូពេទ្យពេលខ្ញុំធំឡើង

កណ្ដាលថ្ងៃត្រង់ព្រះអាទិត្យកំពុងតែបញ្ចេញកំដៅយ៉ាងពេញទំហឹងសូម្បីដីក៏ឡើងក្ដៅស្ទើរតែដាន់មិនបានផងតែមានកុមារីសំបុរខ្មៅស្រអែមស្លៀកសំពត់រហែកពាក់អាវសគ្មានស្បែកជើង យួរថង់ថ្នាស្ទិកហូរញើសស្រោក់ ដើរយ៉ាងលឿនឆ្ពោះទៅថ្នាក់រៀនអ្វីដែលក្នុងថង់នោះគឺជាសម្ភារៈសិក្សា ។ នាងឈ្មោះ ពាយ ពត អាយុ១១ឆ្នាំរៀនថ្នាក់ទី២នៅសាលាបឋមសិក្សាមេត្តាករុណាស្រុកបន្ទាយស្រី ។ កុមារីសំបុរខ្មៅស្រអែមរូបនេះមានការលំបាកលំបិនណាស់ តែបើសួរនាងថា «តើក្មួយរៀនដើម្បីអ្វី?» នាងនឹងឆ្លើយតបទាំងញញឹមថា«ខ្ញុំចង់ធ្វើជាគ្រូពេទ្យពេលខ្ញុំធំឡើង!» ។ ប្រិយមិត្តអ្នកអានជួយគិតមើល! តើនាងអាចសំរេចបំណងបានដែរឬទេ? ស្ថានភាពគ្រួសារកុមារីសំបុរខ្មៅស្រអែមជាកូនស្រីនៃគ្រួសារក្រីក្រលំបាកមួយ ស្ថិតនៅក្នុងភូមិអាចម៌ ឃុំខ្នារសណ្ដាយ ស្រុកបន្ទាយស្រី ខេត្តសៀមរាប ។

នាងរស់នៅក្រោមដំបូលផ្ទះខ្ទមតូចនិងចាស់ទ្រុឌទ្រោមមួយសង់អំពីឈើប្រក់ស្បូវជញ្ជាំងពាសដោយស្បូវហើយនិងក្រាលដោយរនាបឫស្សីមើលទៅគួរអោយសង្វេក ។នៅក្នុងខ្ទមដ៏កំសត់នេះមើលទៅគួរតែសំរាប់ត្រឹមតែពីរឬបីនាក់តែប៉ុណ្ណោះរស់នៅ ប៉ុន្តែជាក់ស្ដែងវាផ្ទុកមនុស្សដល់ទៅ១០នាក់ ។ កុមារី ពត មានឪពុកឈ្មោះ **ហ៊ុយ ពាញ** ម្ដាយឈ្មោះ**ជិន មឿន** ។ ពួកគាត់ពុំសូវមានសុខភាពមាំទាំទេ ជាក់ស្ដែងពេលនេះឪពុកនាងកំពុងតែមានជំងឺទៀតផង ។ ក្រៅពីឪពុកម្ដាយនាង មានបងប្រុស៤នាក់ ប្អូនស្រី២នាក់ហើយនិងមីងពីរនាក់ទៀត ។ គ្រួសារនេះប្រកបរបរធ្វើស្រែបានផលមធ្យម១៨ការ៉ុងក្នុងមួយឆ្នាំ ដែលចំនួននេះអាចផ្គត់ផ្គង់ជីវភាពបានត្រឹមតែ៥ខែប៉ុណ្ណោះ ។





ក្រៅពីនេះពួកគាត់ឆ្លៀតស៊ីឈ្នួលលុបរងឪឡឹក បេះផ្លែឪឡឹក និងកាប់អុស កូនឈើឬក៏ចាប់កណ្ដុរលក់...ៗល ៗ ដើម្បីបានលុយយកមកទិញអង្ករនិងម្ហូបអាហារចំអែតក្រពះ ។ «ជាយូរយាណាស់មកហើយគ្រួសារខ្ញុំដូចជាពុំមានការរីកចំរើនអ្វីសោះឡើយ ក្រៅពីចំនួនកូនដែលចេះតែកើនឡើងស្ទើរតែរាល់ឆ្នាំ ។ «តែទោះជាយ៉ាងណាក៏ដោយខ្ញុំចង់អោយកូនខ្ញុំបានរៀនសូត្រដើម្បីបានចេះដឹងនឹងគេ កុំអោយល្ងង់ដូចខ្ញុំទៀត » លោក **ពាញ** ដែលជាឪពុកបានមានប្រសាសន៍ ។ ស្ដាប់មើលទៅគាត់ដូចជាមានជំនឿចិត្តលើកូនស្រីគាត់រូបនេះណាស់ ។

បើអ្នកធ្វើដំណើរទៅទស្សនាប្រាសាទបន្ទាយស្រីហើយឆៀងចូលតាមផ្លូវលំកាត់ព្រៃតំរង់ទិសពាយព្យលើចំងាយផ្លូវជាង៣គីឡូម៉ែត្រអ្នកនឹងបានឃើញទង់ជាតិព្រះរាជាណាចក្រកម្ពុជាកំពុងបក់រវិចៗ តទំព័រទី៥

N"10.qxd 06/16/2006 10:06 Morning Page V



# គុណម្ដាយ (ត)

## បទកាកគតិ

### ភាគទី៨

ជាតិជាអ្នកក្រ ខំប្រឹងត្រដរ បន្តព្រោះទ្រព្យ
ដោះស្រាយជីវភាព អោយប្រសើរគាប់ ទោះបីគ្មានភ័ព្វ
ក៏ទ្រាំតស៊ូ ។

ធ្វើស្រែចំការ ហត់នឿយយ៉ាងណា អាត្មាត្រូវប្តូរ
បញ្ចេញកម្លាំង ហត់ខ្លាំងមិនថ្ងូរ ព្រោះត្រូវតស៊ូ
ដើម្បីគ្រួសារ ។

ណាមួយគិតកូន ប្រពន្ធមាសស្ងួន ដែលជាមាតា
ឆ្លៀតជួយធ្វើស្រែ ណាថែបុត្រភ្ងា ណាត្រូវធ្វើការ
ងារផ្ទះសម្បែង ។

ខ្លួនជាឪពុក ការងារគ្រប់មុខ ដោះស្រាយស្វះស្វែង
ខំរកទុកដាក់ ក្នុងផ្ទះសម្បែង មួយភ័យខ្លាចក្រែង
ប្រពន្ធកូនឈឺ ។

ថ្ងៃណាកើតទុក្ខ អារម្មណ៍មិនសុខ សំកុកទល់ភ្លឺ
បើក្រក្រចុះ កុំអោយតែឈឺ មិនចង់ដឹងឮ
ជំងឺរោគា ។

ជីវិតអ្នកក្រ ខំទាំងត្រដរ ក៏នៅវេទនា
ធ្វើមិនហ៊ានឈប់ ទាំងឈឺទាំងជា ទោះក្ដៅរងា
ពុះពារអោយហើយ ។

ទោះបីយ៉ាងណា បុត្រទាំងទ្វេហា កុំភ័យព្រួយឡើយ
ពុកនឹងខំរក មិននៅព្រងើយ ជូនកូនដល់ត្រើយ
សុភមង្គល ។

ឪពុកទ្រាំអត់ ទ្រាំការនឿយហត់ មិនអោយកូនយល់
ស្គាល់ក្ដីអត់ឃ្លាន រុករានអំពល់ មានទុក្ខកង្វល់
ខ្វល់ធ្លាក់លើកូន ។

កូនគឺអ្នកឆ្លង ឪពុកម្ដាយផង ត្រងទ្រជាក្បួន
បណ្ដេតកាយា សណ្ដោងរូបកូន កាយគាស់បញ្ជូន
ស្ងួនទាំងទ្វេហា ។

ទោះមានរលក ខ្យល់ព្យុះបក់បោក ប៉ងលើបុត្រា
ឪពុកជាភ្នំ ផ្ដុំរាំងសង្ស្រា អ្នកម្ដាយគឺជា
ម្លប់ពោធិព្រឹក្ស ។

យើងមានពូជពង្ស ត្រកូលគង់វង្ស ថ្វីត្បិតតែក្រ
ទោះបីយ៉ាងណា ម៉ែនឹងត្រដរ អោយកូនបន្ត
សិក្សាដល់ចប់ ។ *នៅមានត*

ដកស្រង់ចេញពីសៀវភៅកំណាព្យគុណឪពុកម្ដាយនិពន្ធដោយ អ្នកស្រី **ខ្លូ ណារី**

# ឪពុកម្ដាយល្អបន្ទុលក្ខណៈ...

*ឡើយគឺមានតែសង្ឃឹមលើលោកគ្រូអ្នកគ្រូដែលជាអ្នកចេះដឹងមានសមត្ថភាពក្នុងការបង្ហាត់បង្រៀនចំនេះដឹងដល់សិស្សតែម៉្យាងគត់ ។ ទន្ទឹមនឹងនោះគាត់ក៏សំណូមពរដល់ឪពុកម្ដាយទាំងឡាយ សូមបង្កលក្ខណៈអោយកូនបានរៀនសូត្រចេះដឹងគ្រប់ៗគ្នាផង ព្រោះយើងជាអ្នកទទួលខុសត្រូវលើវាសនាកូន ។*

*ទោះបីជាជីវិតជួបការលំបាក ជីវភាពខ្វះត់ខ្វែយយ៉ាងណាក្ដី ក្នុងនាមជាមាតាបិតារបស់គេគឺតែងតែមានគំនិតចង់អោយកូនរៀនសូត្រមានចំណេះដឹងខ្ពស់មានអនាគតល្អ មានសុភមង្គល និងមានកិត្តិយសនៅក្នុងសង្គមព្រោះគាត់យល់ថា រូបគាត់ទាំងពីរមកពីល្ងីតល្ងង់ហ្នឹងហើយទើបពិបាកដូច្នេះ ។ នេះជារឿងពិតពីខ្សែជីវិតរបស់លោកពូ ជា ផុន ដែលមានមុខរបរជាអ្នករត់ម៉ូតូឌុបនិងលក់កំពឹងត្នោត រស់នៅភូមិស្ដុក ឃុំភ្នំបាតស្រុក ពញាឮ ខេត្តកណ្ដាល ដែលមានកូនប្រាំនាក់រស់នៅក្នុងបន្ទុក ។ កូនប្រុសអាយុ១៨ឆ្នាំរៀនថ្នាក់ទី១១ កូនស្រីអាយុ១៦ឆ្នាំរៀនថ្នាក់ទី៨ កូនប្រុសអាយុ១១ឆ្នាំរៀនថ្នាក់ទី៤ និងកូនពីរនាក់ទៀតនៅផ្ទះ ។ ដូចនេះបន្ទុកដ៏ធំនេះត្រូវធ្លាក់លើរូបគាត់តែម្ដង ។ តែទោះជាយ៉ាងណាក៏គាត់មិនរួញរាពីការលំបាកនិងរកស៊ីចិញ្ចឹមកូននោះដែរ ។ ទោះបីរូបគាត់ជាម្ដាយក៏គាត់យល់ពីអត្ថប្រយោជន៍នៃការសិក្សាដែរគាត់បានបង្ហាញពីគំនិតរបស់គាត់គឺគាត់ចង់អោយកូនរបស់គាត់ទាំងអស់រៀនដល់ថ្នាក់មហាវិទ្យាល័យ ព្រោះសព្វថ្ងៃប្រសិនបើយើងមានកំរិតចំណេះដឹងខ្ពស់យើងក៏ទួលបាននូវការងារល្អប្រាក់បៀវត្សក៏ខ្ពស់ ។*

*តទំព័រទី៦*

N"10.qxd 06/16/2006 10:06 Morning Page VI

# ខ្ញុំចង់ធ្វើជាគ្រូពេទ្យ...

ហាក់ដូចជាកំពុងបក់ដៃអន្ទងចិត្តភ្ញៀវទេសចរណ៍អោយចូលមកទីកន្លែងនោះ ។ លុះចូលដល់ជិតបន្ទិចអ្នកនឹងបានឃើញអាគារថ្មប្រក់ក្បឿងមួយខ្នងឈរយ៉ាងសង្ហារគួរជាទីគយគន់ ។នេះហើយជាសាលាបឋមសិក្សាមេត្តាករុណា ។ នៅក្នុងបរិវេណសាលា មានសម្មិទ្ធិផលជាច្រើនដែលសុទ្ធសឹងជាស្នាដៃដ៏មានអត្ថន័យថ្លៃថ្លារបស់អង្គការមេត្តាករុណាជូនចំពោះកូនខ្មែរគ្រប់រូបដ៏គួរអោយអាណិតនៅក្នុងមជ្ឈដ្ឋានជុំវិញ ។ ហេតុអ្វីទៅបានជាគួរឲ្យអាណិតពួកគេ? **ការសិក្សារៀនសូត្រ** ថ្វីត្បិតតែការធ្វើដំណើរមកសាលារៀនជួបប្រទះនឹងការលំបាកច្រើន តែកុមារី **៣ញ ពត**តែងមករៀនទៀងទាត់មិនដែលខកខានឡើយ ។ ផ្ទះនាងនៅឆ្ងាយ នាងគ្មានកង់សំរាប់ជិះ ហើយក៏គ្មានអ្នកផ្ទះឌុបមក សាលារៀនដែរ តែនាងមិនត្អូញតែឡើយ គឺសុំត្រឹមតែមានឱកាសមកសាលារាល់ថ្ងៃនាង សប្បាយចិត្តណាស់ទៅហើយព្រោះពេលខ្លះនាងប្រាប់ថា « ម្ដាយឪពុកខ្ញុំបានឃាត់ខ្ញុំមិនអោយមកសាលាម្ដងពីររួចទៅហើយ តែខ្ញុំនៅតែឆ្លៀតមករៀន ដោយទុកកិច្ចការនោះធ្វើពេលក្រោយ ឬខ្ញុំខំធ្វើអោយហើយមុនពេលមកសាលា ។ ជូនកាលខ្ញុំមករៀនទាំងបំពាន »

នៅសាលានាងតែងតែចូលរួមសកម្មភាពសិក្សារៀនសូត្រដោយយកចិត្តទុកដាក់ ។ទោះជាខួរក្បាលនាងពុំសូវវាងវៃ តែនាងនៅមិនទាន់ចុះចាញ់មិនព្រមបោះបង់ការព្យាយាមឡើយ ។ នាងតែងមានក្ដីសង្ឃឹមជាប់ជានិច្ច ។ ពេលចេញលេងនាងតែងចេញលេងជួបជុំជាមួយមិត្តភក្តិដោយប្រកាន់ភាពស្មោះត្រង់ជានិច្ច ។ នាងពុំដែលឈ្លោះប្រកែកជាមួយនរណាម្នាក់ឡើយ ។ អាស្រ័យដោយការយកចិត្តទុកដាក់ លទ្ធផលការងារនិងចរិតស្លូតបូតរបស់នាងធ្វើឲ្យមនុស្សគ្រប់គ្នានៅក្នុងសាលាជាពិសេសគឺរូបខ្ញុំផ្ទាល់មានការស្រលាញ់ពេញចិត្តនាងជាខ្លាំង ហើយជាលទ្ធផលនាងបានជាប់ជាសិស្សពូកែម្នាក់ក្នុងចំណោមសិស្សពូកែទាំងប្រាំនាក់ប្រចាំថ្នាក់រៀន ។

នៅបំណាច់ឆ្នាំសិក្សា២០០៤- ២០០៥ នេះនាងបានជាប់ចំណាត់ថ្នាក់លេខ៣ហើយបានទទួលរង្វាន់លើកទឹកចិត្តពីសាលានិងពីអង្គការមជ្ឈមណ្ឌលមេត្តាករុណាថែមទៀតផង ។ នាងសប្បាយចិត្តណាស់ថែមទាំងបានប្ដេជ្ញានៅចំពោះមិត្តរួមថ្នាក់រួមសាលាថា“ឆ្នាំក្រោយខ្ញុំនឹងតស៊ូយកចំណាត់ថ្នាក់លេខ១ឲ្យទាល់តែបាន” ។

ទោះជាយ៉ាងណាក៏ដោយនាងនៅតែឆ្លៀតពេលទំនេរដើម្បីជួយសំរួលកិច្ចការឪពុកម្ដាយរបស់នាង ជូនកាលនាងបានទៅស៊ីឈ្នួលគេដើម្បីយកប្រាក់ជួយសំរួលដល់ជីវភាពគ្រួសារផងដែរ ដូចជា បេះផ្លែឪឡឹកជាដើម ។

សំណូមពរ ដោយឃើញគំរូវិរភាពរបស់កុមារីរូបនេះ ក្នុងនាមខ្ញុំជាគ្រូបង្រៀនរបស់នាងមួយរូប សូមសំណូមពរនិងទទូចអង្វរសុំអោយមាតាបិតាសិស្សរូបនេះក៏ដូចជាមាតាបិតាសិស្សទូទៅដែរ សូមមេត្តាផ្ដល់ឱកាសអោយកូនបានរៀនសូត្រជ្រៅជ្រះព្រោះថា មានតែចំណេះវិជ្ជានេះហើយដែលជាទ្រព្យដ៏គាប់ប្រសើរបំផុតរបស់ពួកគេ ។ បើមិនគិតថាធ្វើដើម្បីពួកគេ ក៏គិតថាធ្វើដើម្បីខ្លួនឯងផងទៅចុះ ព្រោះថា ពេលណាកូនរៀនបានខ្ពង់ខ្ពស់មានការងារល្អធ្វើមានប្រាស់កាសសំបូរហូរហៀរពេលនោះពួកគេប្រាកដជានឹកឃើញដល់ឪពុកម្ដាយរបស់ពួកគេហើយតបស្នងសងគុណលោកអ្នកមានគុណវិញជាមិនខាន ។

ហើយចំពោះកុមារាកុមារីវិញសូមប្អូនៗខិតខំតស៊ូរៀនសូត្រដោយយកចិត្តទុកដាក់ទាំងនៅ សាលា និងនៅផ្ទះ ។ ហើយត្រូវចេះជួយការងារផ្ទះផងដែរតែមិនត្រូវភ្លេចខ្លួនមិនមកសាលារៀននោះឡើយសុមប្អូនៗធ្វើចិត្តអោយធំតស៊ូរៀនសូត្រអោយដល់ទីបំផុតកុំអស់សង្ឃឹមអោយសោះ គង់មានថ្ងៃណាមួយយើងនឹងបានទទួលជោគជ័យដូចមានកុមារី ពត ជាគំរូស្រាប់ ។

ជាចុងក្រោយសូមសំណូមពរអោយអង្គការមជ្ឈមណ្ឌលមេត្តាករុណាមេត្តាបន្តជួយកុមារដែលជួបការលំបាកទាំងឡាយអោយគ្នាបានរៀនសូត្រជ្រៅជ្រះនិងគេតាមរយៈសម្ភារៈ ថវិកាស្មារតី ។ល ។ តាមដែលអាចធ្វើទៅបាន ព្រោះមានតែកុមារនេះហើយដែលអាចក្រោកឈរ ជាជំហរដ៏រឹងមាំចូលរួមគ្នាអភិវឌ្ឍន៍ប្រទេសកម្ពុជាយើងអោយបានកាន់តែប្រសើរឡើងតទៅអនាគត ។

ដោយភីង ពៅ បន្ទាយស្រី សៀមរាប

N"10.qxd 06/16/2006 10:06 Morning Page VII

# ឪពុកម្តាយល្អបង្កលក្ខណៈ...

ដូច្នេះហើយស្ត្រីជាម្តាយដូចរូបគាត់បានយល់ពីការលំបាក ទុក្ខវេទនានៅក្នុងជីវិតនេះគឺបណ្តាលមកពីភាពអវិជ្ជារបស់គាត់ទើបរូបគាត់មិនចង់ឃើញកូនៗមានការលំបាកដូចរូបគាត់ទាំងពីរ ។

ដូច្នេះហើយទើបរូបគាត់តស៊ូអោយកូនរៀនសូត្រដោយមិនគិតពីការលំបាកនឿយហត់ឡើយ ។ គាត់បានបញ្ជាក់ថា ដាក់ទៅលើការចំណាយក្នុងមួយថ្ងៃគាត់អាចសន្សំទុកបាន៥០០០រៀលក្នុងមួយថ្ងៃ។ ប្រាក់សន្សំនេះហើយដែលគាត់ទុកបំរុងពេលមានជំងឺឬតម្រូវការរបស់កូនៗក្នុងការសិក្សា ។

នេះសរបញ្ជាក់អោយឃើញថាមាតាបិតាដូចជារូបគាត់ទាំងពីរពិតជាតស៊ូដើម្បីកូន ដើម្បីអនាគត សុភមង្គលនិងកិត្តិយសរបស់កូនក៏ដូចជាក្រុមគ្រួសាររបស់គាត់ដែរ ។

បើយើងជាបុត្រធីតា តើយើងហ៊ានលះបង់ដូចជារូបគាត់ដែរឬទេ? តើការលះបង់នោះរបៀបណាដែរ?

ដូច្នេះក្នុងនាមជាបុត្រធីតា តើយើងត្រូវធ្វើការតបស្នងទៅមាតាបិតាដោយរបៀបណា ពេលយើងស្ថិតនៅជាសិស្សនៅឡើយនោះ?

ហេតុដូចម្តេច បានជាមាតាបិតាត្រូវគិតពីអនាគតរបស់បុត្រធីតា?

ជាបុត្រធីតា តើយើងត្រូវធ្វើយ៉ាងណាដើម្បីអោយមាតាបិតាសប្បាយចិត្ត? កិច្ចតបស្នងរបស់យើងជាកូនចំពោះមាតាបិតាមានអ្វីខ្លះ?

ចាក់ផ្សាយតាមរលកវិទ្យុព្រហ្មមានជ័យ
ខេត្តបន្ទាយមានជ័យថ្ងៃទី ២៦ ខែសីហា ឆ្នាំ ២០០៥
យកពត៌មានដោយលោក នឿន តុងលាង
រៀបរៀងដោយ សុខ អេង បន្ទាយមានជ័យ

# ប្រសិទ្ធិភាពប្រាក់កម្ចីរបស់សមាគមសា

ផ្ទះតៀមថ្មប្រក់ក្បឿងមួយខ្នងដែលលំអទៅដោយវាលស្រែមានពណ៌បៃតងខ្ចី នៅរដូវវស្សា ដើមក្រខុប, ដើមស្វាយ, ស្រះចិញ្ចឹមត្រី, ម៉ាស៊ីនបញ្ចូលអាគុយ, ម៉ាស៊ីនកិនស្រូវខ្នាតតូច, ទ្រុងជ្រូក,រោងបិតស្រា,រោងផ្សារអេឡិចត្រូនិច, ទីតាំងលក់ប្រេងសាំង ម៉ាហ្សូត និងកន្លែងប៉ះកង់,ម៉ូតូទាំងអស់នេះជាផ្លែផ្កានៃការខិតខំប្រឹងប្រែងទាំងយប់ទាំងថ្ងៃរបស់លោក សុខ សំណាង អាយុ ៣៥ ឆ្នាំ ព្រមទាំងភរិយា របស់គាត់ សៀង សឿង អាយុ២៩ឆ្នាំមានកូន៣នាក់ក្នុងបន្ទុកនិងមានលទ្ធភាពឲ្យកូនៗ ២ នាក់ទៅសាលារៀន ។

បច្ចុប្បន្នក្រុមគ្រួសារមួយនេះរស់នៅ ភូមិព្រៃឈើទាល, ឃុំសំរោងលើ, ស្រុកអង្គស្នួល, ខេត្តកណ្តាល ចម្ងាយប្រមាណជាង ៣ គីឡូម៉ែត្រពីទីប្រជុំជន ផ្សារអង្គស្នួល ។



ដំបូងឡើយលោកសំណាងបានរស់នៅរួមគ្នាជាមួយបងបង្កើត ហើយបានខ្ចីប្រាក់ខ្លះពីសមាគមសាមគ្គីកសិករក្រីក្រក្រោមការឧបត្ថម្ភ ពីអង្គការ JS ។ ប្រាក់ចំនួន ១០០.០០០៛ ប៉ុណ្ណោះ សំរាប់យកមកធ្វើដើមសំរាប់ដឹកស្ករលក់,បិតស្រានិងចិញ្ចឹមជ្រូក ។លោកមានប្រសាសន៍ថា "កាលណោះជារៀងរាល់ថ្ងៃក្រៅពីរបរធ្វើស្រែខ្ញុំបានចុះទិញស្ករតាមភូមិនានា រួចដឹកតាមកង់យកទៅលក់នៅ

N"10.qxd 06/16/2006 10:06 Morning Page VIII

# ស់សមាគមសាមគ្គីកសិករក្រីក្រ



ផ្សារដេប៉ូ,ក្រុងភ្នំពេញរីឯភរិយាជាមេផ្ទះនៅជួយថែភ្លើងបិតស្រា និងចិញ្ចឹមជ្រូក២ក្បាលផង ។ របររកស៊ីរបស់ខ្ញុំពីមួយថ្ងៃទៅមួយថ្ងៃ បានទទួលផលកំរៃចំណេញកើនឡើងនិងរីកចំរើនបន្តិចម្តងៗជាលំដាប់ ។ ក្រៅពីប្រើពេលវេលាប្រកបរបរផ្ទាល់ខ្លួន ពេលខ្លះខ្ញុំតែងតែជួយពន្យល់ណែនាំផ្តល់ជាគំនិតយោបល់ខ្លះៗដល់សមាជិកសមាគមយើងខ្ញុំមួយចំនួនស្តីពីរបៀបរបររកស៊ីរកប្រាក់កំរៃចំណេញទុកសំរាប់ផ្គត់ផ្គង់សេដ្ឋកិច្ចគ្រួសារផង និងបង្វិលប្រាក់ដើមនិងប្រាក់ការទុកសងសមាគមនៅពេលបិទវគ្គផង» ។ លោកបន្ថែមទៀតថាៈតាំងតែពីគាត់បានចាកចេញពីក្នុងភូមិមកគាត់រៀបចំបង្កើអោយមានលក្ខណៈបច្ចេកទេស អាចឲ្យគាត់រៀបចំនូវមុខរបរចំរុះជាប្រព័ន្ធនៅ លើទីកដីប្រមាណ៤អារជាប់ផ្លូវកែងបត់ចូលទៅភូមិដូនម៉ាន់ ។ នៅក្នុងបរិវេណមានរោងប្រក់ស្លឹកសំរាប់ដាក់ម៉ាស៊ីនសំរាប់បញ្ចូលភ្លើងអាគុយខាងស្តាំច្រកទ្វាររបងចូលផ្ទះមានរោងស្លឹកមួយទៀតដាក់ឡែងដាក់ធុងលក់ប្រេងសាំង, ប្រេងម៉ាហ្សូត និងដាក់ឡែងប៉ះកង់, ម៉ូតូ និងផ្សារអេឡិចត្រូនិចផង ។ ម៉ាស៊ីនកិនស្រូវខ្នាតតូចមួយដោយគាត់ដើរប្រមូលស្រូវអ្នកភូមិរបស់គាត់មកកិនដោយយកតែកន្ទក់ និងចុងអង្ករសម្រាប់បិតស្រា, ធ្វើជាចំណីជ្រូក និងចំណីត្រីប៉ុណ្ណោះ ។ ប៉ុន្តែនាពេលសព្វថ្ងៃនេះ សន្ទុះផលិតកម្មមានការថយចុះបន្តិច ដោយផ្អែកទៅលើទិន្នផលស្រូវឆ្នាំកន្លងប្រជាកសិករយើងជួបប្រទះគ្រោះរាំងស្ងួតរោងបិតស្រាដែលក្នុង១ថ្ងៃចំហុយបានជាស្រាស១កានចំណុះ៣០លីត្រនិងការ ។ សព្វថ្ងៃនេះគាត់ចិញ្ចឹមជ្រូកពូជខ្មែរ ដែលងាយស្រួលក្នុងការបំប៉នចំណីហើយមានការងាយស្រួលក្នុងការព្យាបាលនៅពេលមានជម្ងឺ លទ្ធផល ត្រូវចំណេញ ៥០ភាគរយលើប្រាក់លក់ចេញជ្រូក១ក្បាល ។ ប្រការនេះគឺដោយសារគាត់ ប្រើចំណីបំប៉នបានពី ម៉ាស៊ីនកិនស្រូវ ដូចជាចុងអង្ករ និងកន្ទក់ រួមទាំងកាកសំណល់បាយស្រា ។ គាត់មានគំរោងស្តារស្រះ និង ទិញកូនត្រីចិញ្ចឹម ។ល។ ជាការពិតណាស់ថា ពាក្យចាស់បុរាណមួយពោលថា ធ្វើអ្វីត្រូវធ្វើឲ្យពិតប្រាកដយ៉ាងណាមិញការប្រឹងប្រែងក្នុងវិស័យជាកសិករផង ជាកម្មករពិតប្រាកដដូចរូប លោកសំណាងនេះ បានធ្វើអោយជីវភាពរបស់គាត់មានការប្រែប្រួលយ៉ាងខ្លាំង ។

លោកបានបញ្ជាក់ថាៈ តាំងតែពីខ្ញុំបេះប្ដូជីវិតអោយផ្សាភ្ជាប់ជាមួយវិស័យកសិកម្មទៅនឹងរបរបន្ទាប់បន្សំនេះមកជីវភាពរបស់គ្រួសារខ្ញុំមានការរីកចំរើននិងកើនឡើងពីមួយឆ្នាំ ទៅមួយឆ្នាំ ។ ខ្ញុំលែងព្រួយបារម្ភអ្វីទៀតហើយ ខ្ញុំនឿយហត់មែនប៉ុន្តែគ្រួសារខ្ញុំមានសុភមង្គល ។

លោកសំណាងមានប្រសាសន៍ដោយបញ្ចេញនូវស្នាមញញឹមតិចៗបន្តប់ទៅដោយសេចក្តីសង្ឃឹមមុតមាំចំពោះអនាគតគ្រួសាររបស់គាត់ ។ ចំណែកឯអ្នកស្រី **សៀង សៀង**ភរិយារបស់លោកដែលខិតខំតស៊ូទាំងអស់គ្នាដើម្បីឲ្យចាកផុតពីភាពក្រីក្រនោះ បាននិយាយថា ពួកគាត់ដែលជាឪពុកម្តាយខិតខំប្រឹងប្រែងណាស់ទោះបីជាហត់នឿយយ៉ាងណាក៏ដោយក៏តស៊ូអត់ទ្រាំដែរ ។ ប្រជាជននៅក្នុងឃុំសំរោងលើទាំងមូលមានការកោតសរសើរយ៉ាងខ្លាំងចំពោះក្រុមគ្រួសារលោក សំណាង ដែលខិតខំខ្សស្បាហ៍ព្យាយាមសំរេចតាមគោលបំណងដែលបានគ្រោងទុកជាគំរូមួយសំរាប់សមាជិកសមាគមសាមគ្គីកសិករក្រីក្រដទៃទៀតរៀនសូត្រតាមហើយក៏ជាសកម្មភាពមួយរួមចំណែកយ៉ាងសកម្មក្នុងការបំបាត់ភាពក្រីក្រ អភិវឌ្ឍន៍សហគមន៍ជនបទ និងកសាងប្រទេសឈានទៅរកភាពសម្បូរសប្បាយជឿនលឿននិងរីកចំរើន ។

ដោយ ឡុង សុផល